# ឧរគបេតវត្ថុ




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ឧរគោវ តចំ ជិណ្ណំ** *ដូច្នេះជាដើម ។*

*បានឮមកថា ក្នុងក្រុងសាវត្ថី មានបុត្ររបស់ឧបាសកម្នាក់ ធ្វើកាលកិរិយា ។ ហេតុតែបុត្រស្លាប់ ឧបាសកនោះដល់នូវសេចក្តីសោក និងការយំខ្សឹកខ្សួល មិនអាចចេញទៅក្រៅដើម្បីធ្វើការងារអ្វីឡើយ គាត់នៅតែក្នុងផ្ទះប៉ុណ្ណោះ ។*

*លំដាប់នោះ ព្រះសាស្តាចេញពី***មហាករុណាសមាបត្តិ** *ក្នុងវេលាបច្ចូសសម័យ ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏ឃើញឧបាសកនោះ, ក្នុងបុព្វណ្ហសម័យ ទ្រង់ស្បៀកដណ្តប់ កាន់យកបាត្រនិងចីវរ យាងទៅផ្ទះឧបាសកនោះ ហើយប្រថាប់ឈរនៅជិតទ្វារ ។*

*ឧបាសកឮថាព្រះសាស្តាយាង ក៏ក្រោកឡើងដោយរហ័ស ទៅទទួលដំណើរ កាន់យកបាត្រពីព្រះហស្តព្រះសាស្តា និមន្តព្រះអង្គឲ្យយាងចូលផ្ទះ រៀបចំក្រាលថ្វាយអាសនៈ ។ ព្រះ*

មានព្រះភាគប្រថាប់លើអាសនៈ ដែលឧបាសករៀបចំថ្វាយ ។ ចំណែកឧបាសកថ្វាយបង្គំព្រះភគវន្តហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាសក តើអ្នកមានសេចក្តីសោកឬ? ឧបាសកទូលថា បពិត្រព្រះមានព្រះភាគ ពិតមែនហើយ បុត្រជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គធ្វើកាលកិរិយា ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គសោយសោក ។ ពេលនោះ ព្រះមានព្រះភាគកាលនឹងធ្វើការបន្ទោបង់សេចក្តីសោករបស់ឧបាសកនោះ ទើបត្រាស់សម្តែង**ឧរគជាតក** (បញ្ចកនិបាត មណិកុណ្ឌលវគ្គ) ថា

ក្នុងអតីតកាល មានព្រាហ្មណត្រកូលឈ្មោះ **ធម្មបាល** ក្នុងនគរពារាណសី ដែនកាសី ក្នុងត្រកូលនោះ មានព្រាហ្មណ៍ ព្រាហ្មណី បុត្រ ធីតា កូនប្រសាស្រី និងទាសី មនុស្សទាំងអស់នេះ សុទ្ធតែជាអ្នកត្រេកអរនឹងការចម្រើនមរណានុស្សតិ ។ បណ្តាមនុស្សទាំងនោះ ជនណាចេញពីផ្ទះ ជននោះតែងឲ្យឱវាទជនដ៏សេស ជាអ្នកមិនមានការអាឡោះអាល័យ ហើយទើបចេញទៅ ។

ថ្ងៃមួយ ព្រាហ្មណ៍មួយអន្ទើដោយបុត្រចេញពីផ្ទះ ទៅស្រែ ភ្ជួររាស់ ។ បុត្រដុតស្មៅស្ងួកឈើ និងឈើងាប់ ។ ក្នុងទីនោះ មានពស់វែកក្របីមួយ ចេញពីប្រហោងឈើ ដោយភ័យខ្លាចភ្លើងឆេះ មកចឹកបុត្ររបស់ព្រាហ្មណ៍ ។ ដោយកម្លាំងនៃពិស បុត្រនោះស្តុត ហើយដួលចុះ ធ្វើកាលកិរិយាក្នុងទីនោះឯង បានទៅកើតជាសក្កទេវរាជ ។ ព្រាហ្មណ៍ឃើញបុត្រស្លាប់ហើយ ក៏ពោលនឹងបុរសម្នាក់ដែលកំពុងដើរទៅក្នុងទីជិតការងារ យ៉ាងនេះថា នែសម្លាញ់សូមទៅផ្ទះខ្ញុំ ពោលយ៉ាងនេះនឹងព្រាហ្មណីថា ចូរងូតទឹក ស្លៀកសំពត់ស នាំអាហារសម្រាប់បុគ្គលតែម្នាក់ និងនាំកម្រងផ្កា គ្រឿងក្រអូបជាដើម ហើយចូរប្រញាប់មក ។

បុរសនោះទៅហើយ បានប្រាប់យ៉ាងនោះ សូម្បីជនក្នុងផ្ទះក៏បានធ្វើយ៉ាងនោះ ។ ព្រាហ្មណ៍មុជទឹក ហើយបរិភោគអាហារ រួចលាបគ្រឿងក្រអូប មានជនដ៏សេសជាបរិវារ លើកសរីរៈបុត្រដាក់លើជើងថ្ករ បូជាសព ជាអ្នកមិនមានសេចក្តីសោក មិនក្តៅក្រហាយ ហាក់ដូចជាដុតគំនរឧស ឈរធ្វើអនិច្ចសញ្ញាក្នុងចិត្ត ។

*លំដាប់នោះ បុត្ររបស់ព្រាហ្មណ៍ដែលកើតជាសក្កទេវរាជនោះ បុត្រនោះ គឺជាព្រះពោធិសត្វរបស់យើងហ្នឹងឯង ។ សក្កទេវរាជពិចារណាបុណ្យ ដែលបានធ្វើក្នុងជាតិមុនរបស់ខ្លួនហើយ កាលនឹងអនុគ្រោះបិតា និងពពួកញាតិ ក៏មកក្នុងទីនោះដោយភេទជាព្រាហ្មណ៍ ឃើញពួកញាតិមិនសោយសោក ទើបពោលថា នៃអ្នកដ៏ចម្រើន ពួកលោកដុតម្រឹគឬ សូមឲ្យសាច់ដល់ខ្ញុំផង ខ្ញុំឃ្លានណាស់ ។*

***ព្រាហ្មណ៍ជាបិតាពោលថា*** *នៃព្រាហ្មណ៍ នេះមិនមែនម្រឹគទេ គឺជាមនុស្ស ។*

***សក្កទេវរាជសួរថា*** *គេជាសត្រូវរបស់លោកឬ ?*

***ព្រាហ្មណ៍ពោលថា*** *គេនោះមិនមែនជាសត្រូវទេ គេជាកូនដែលនៅក្មេង ជាអ្នកមានគុណច្រើន ជាឱរសដែលកើតពីទ្រូង ។*

***ព្រះឥន្ទពោធិសត្វពោលថា*** *បើគេជាអ្នកមានគុណបែបនេះ ព្រោះហេតុអ្វី លោកទើបមិនសោយសោកនឹងបុត្រដែលនៅក្មេងស្លាប់ ?*

*ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ កាលនឹងសម្តែងហេតុនៃការមិនសោក ទើបពោល ២ គាថាថា*

**ឧរគោវ តចំ ជិណ្ណំ, ហិត្វា គច្ឆតិ សំ តនុំ;**
**ឯវំ សរីរេ និព្ភោគេ, បេតេ កាលកតេ សតិ។**

*ពស់តែងសកសំណកចាស់របស់ខ្លួនចោលហើយ លូនទៅ យ៉ាងណាមិញ (សត្វ) កាលបើសរីរៈប្រើការមិនកើតហើយ ធ្វើនូវមរណកាល ទៅកាន់បរលោក ក៏យ៉ាងនោះ ។*

**ឌយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ,**
**តស្មា ឯតំ ន រោទាមិ, គតោ សោ តស្ស យា គតិ។**

*(ឯសរីរៈដែលនៅសល់ខាងអាយនោះ ) កាលគេដុត ក៏មិនបានដឹង ( ធ្វើម្តេចនឹងដឹង) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយបាន ហេតុនោះ ខ្ញុំមិនសោកស្តាយសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។*

*កាលព្រាហ្មណ៍ពោលហេតុ នៃការមិនសោករបស់ខ្លួន និងប្រកាសការឈ្វាសក្នុង មនសិការដោយបរិយាយហើយ ស្តេចសក្កៈក៏ពោលនឹងព្រាហ្មណីថា នៃនាងម្ចាស់ គេនោះ ត្រូវជាអ្វីនឹងនាង ?*

***ព្រាហ្មណីពោលថា*** *បពិត្រលោកម្ចាស់ គេជាបុត្រ ដែលខ្ញុំរក្សាដោយផ្ទៃ ១០ ខែ ឲ្យផឹក ទឹកដោះ បីបាច់ថ្នាក់ថ្នមដៃនិងជើង រហូតដល់ធំ ។*

***ព្រះឥន្ទ្រពោលថា*** *ដំបូងឡើយ បើថាបិតាមិនយំ ព្រោះភាពជាបុរស ចុះធម្មតាមាតា ដែលជាអ្នកមានចិត្តទន់នោះ ព្រោះហេតុអ្វី នាងទើបមិនយំដែរ ?*

*នាងព្រាហ្មណីស្តាប់ពាក្យនោះហើយ កាលនឹងសម្តែងហេតុនៃការមិនយំ ទើបពោល ២ គាថា ថា*

អនព្ភិតោ តតោ អាគា, ជានុញ្ញាតោ ឥតោ គតោ;
យថាគតោ តថា គតោ, តត្ថ កា បរិទេវនា។

*បុត្ររបស់ខ្ញុំនេះ ខ្ញុំមិនបានហៅគេមកអំពីលោកនោះ ខ្ញុំមិនបានអនុញ្ញាត គេក៏ទៅ អំពីមនុស្សលោកនេះ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការទួញយំធ្វើអ្វី ព្រោះកិរិយា ទៅនោះ ។*

ឌយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ,
តស្មា ឯតំ ន រោទាមិ, គតោ សោ តស្ស យា គតិ។

*(ឯសរីរៈដែលនៅសល់ខាងអាយនោះ) គេដុតក៏មិនបានដឹង (ធ្វើម្ដេចនឹងដឹង) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំទួញនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។*

*ពាក្យថា **ការទួញយំធ្វើអ្វី ព្រោះកិរិយាទៅនោះ** សេចក្ដីថា យំធ្វើអ្វី ព្រោះអាស្រ័យនឹងមរណៈ ក្នុងការអន្ទោលទៅក្នុងសង្សារវដ្ដ ដែលមិនឋិតក្នុងអំណាចយ៉ាងនេះ ព្រាហ្មណីសម្ដែងថា ការយំនោះមិនសមគួរដល់អ្នកមានបញ្ញាឡើយ ។*

*ព្រះឥន្ទ្រាធិរាជស្ដាប់ពាក្យនាងព្រាហ្មណីហើយ សួរប្អូនស្រីបុត្រនោះថា នែនាង គេនោះត្រូវជាអ្វីនឹងនាង ?*

***ភគិនីពោលថា** បពិត្រលោកម្ចាស់ គាត់ជាបងប្រុសរបស់ខ្ញុំ ។*

***ស្ដេចសក្កទេវានមិន្ទពោលថា** នែនាង ឈ្មោះថា ប្អូនស្រីតែងមានសេចក្ដីស្រឡាញ់ក្នុងបងប្រុស ចុះនាងព្រោះហេតុអ្វី ទើបមិនយំ ?*

*ភគិនីនោះកាលនឹងសម្ដែងហេតុនៃការមិនយំ ទើបពោល ២ គាថាថា*

**សចេ រោទេ កិសា អស្សំ, តត្ថ មេ កិំ ផលំ សិយា;**
**ញាតិមិត្តសុហជ្ជានំ, ភិយ្យោ នោ អរតី សិយា។**

*បើខ្ញុំយំ ខ្ញុំនឹងទៅជាស្គម ក្នុងការយំនោះ នឹងគប្បីមានផលដូចម្ដេចដល់ខ្ញុំ សេចក្ដីមិនត្រេកអរដ៏លើសលុប នឹងគប្បីមានដល់ពួកញាតិមិត្ត និងអ្នកមានចិត្តល្អ របស់យើង ទាំងឡាយ ។*

**ឌយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ,**
**តស្មា ឯតំ ន រោទាមិ, គតោ សោ តស្ស យា គតិ។**

(ឯសរីរៈដែលសល់នៅខាងអាយនោះ) កាលគេដុតក៏មិនបានដឹង (ធ្វើម្ដេចនឹងដឹង) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

សក្កទេវរាជស្ដាប់ពាក្យរបស់ប្អូនស្រីយ៉ាងនេះហើយ សួរភរិយាថា គេនោះត្រូវជាអ្វីនឹងនាង ?

*ភរិយាពោលថា* បពិត្រលោកម្ចាស់ គាត់ជាស្វាមីរបស់ខ្ញុំ ។

*ព្រះឥន្ទពោលថា* នែនាងដ៏ចម្រើន ឈ្មោះថា ស្ត្រីទាំងឡាយជាអ្នកមានសេចក្ដីស្នេហានឹងស្វាមី កាលគេស្លាប់ហើយ នាងជាស្ត្រីមេម៉ាយអនាថា ព្រោះហេតុអ្វី នាងទើបមិនយំ ?

ភរិយាកាលនឹងសម្ដែងហេតុនៃការមិនយំ ទើបពោល ២ គាថាថា

យថាបិ ទារកោ ចន្ទំ, គច្ឆន្តមនុរោទតិ;
ឯវំសម្បទមេវេតំ, យោ បេតមនុសោចតិ។

បុគ្គលណាសោកស្ដាយ នូវបុគ្គលដែលធ្វើមរណកាលទៅ កាន់បរលោកហើយ បុគ្គលនោះ ប្រៀបដូចជាទារកយំទារនូវព្រះចន្ទ្រដែលកំពុងចរទៅ ។

ឧយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ,
តស្មា ឯតំ ន រោទាមិ, គតោ សោ តស្ស យា គតិ។

(ឯសរីរៈដែលសល់នៅខាងអាយនោះ) កាលគេដុតក៏មិនបានដឹង (ធ្វើម្ដេចនឹងដឹង) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

*ស្តេចសក្កៈស្តាប់ពាក្យករិយាយ៉ាងនេះហើយ ក៏សួរទៅនាងទាសីថា នែនាង គេត្រូវជាអ្វី ?*

***នាងទាសីពោលថា*** *បពិត្រលោកម្ចាស់ គាត់ជាចៅហ្វាយនាយរបស់ខ្ញុំ ។*

***សក្កទេវរាជពោលថា*** *បើយ៉ាងនោះ នាងប្រហែលជាត្រូវគេវាយ ហើយប្រើឲ្យធ្វើការងារ ព្រោះហេតុនោះ នាងទើបមិនយំ ដោយសម្គាល់ថា យើងរួចផុតពីគេហើយ ។*

***នាងទាសីពោលថា*** *បពិត្រលោក ចូរកុំពោលយ៉ាងនេះនឹងខ្ញុំឡើយ ពាក្យទាំងនេះមិនសមគួរទេ អយ្យបុត្ររបស់ខ្ញុំជាអ្នកដល់ព្រមដោយខន្តី មេត្តា និងករុណាដ៏ក្រៃលែង ជាអ្នកពោលពាក្យដែលសមគួរ ហាក់ដូចជាបុត្រដែលចម្រើនធំធាត់នឹងទ្រូង ។*

***សក្កទេវរាជពោលថា*** *បើចឹង ព្រោះហេតុអ្វី នាងទើបមិនយំ ?*

*នាងទាសីកាលនឹងសម្តែងហេតុនៃការមិនយំរបស់ខ្លួន ទើពោល ២ គាថា*

**យថាបិ ព្រហ្មេ ឧទកុម្ភោ, ភិន្នោ អប្បដិសន្ធិយោ;**
**ឯវំសម្បទមេវេតំ, យោ បេតមនុសោចតិ។**

*បពិត្រព្រាហ្មណ៍ ក្អមទឹកដែលបែកហើយតភ្ជាប់វិញមិនបាន យ៉ាងណា សរីរៈអ្នកស្លាប់នេះក៏យ៉ាងនោះដែរ បុគ្គលណា សោកស្តាយនូវបុគ្គល ដែលទៅកាន់បរលោកហើយ (បុគ្គលនោះក៏ដូចជាអ្នកសោកស្តាយនូវក្អមដែលបែកហើយដែរ) ។*

**ឧយ្ហមានោ ន ជានាតិ, ញាតីនំ បរិទេវិតំ,**
**តស្មា ឯតំ ន រោទាមិ, គតោ សោ តស្ស យា គតិ។**

(ឯសរីរៈដែលសល់នៅខាងអាយនោះ) កាលគេដុត ក៏មិនបានដឹង (ធ្វើម្តេចនឹងដឹង) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

សក្កទេវរាជស្តាប់ពាក្យរបស់ជនទាំងនោះហើយ ទ្រង់មានចិត្តជ្រះថ្លា ហើយត្រាស់ថា បពិត្រសម្មទេព មរណស្សតិចម្រើនដល់អ្នកទាំងឡាយហើយ ចាប់ពីពេលនេះទៅ កិច្ចដោយការធ្វើកសិកម្មជាដើម រមែងមិនមានដល់អ្នកទាំងឡាយឡើយ ដូច្នេះទ្រង់ទើបធ្វើរតនៈ ៧ ប្រការឲ្យពេញក្នុងផ្ទះរបស់ជនទាំងនោះ រួចឲ្យឱវាទថា អ្នកទាំងឡាយចូរកុំប្រមាទ ចូរឲ្យទាន រក្សាសីល និងនាំគ្នាធ្វើឧបោសថកម្មចុះ ពោលដូច្នេះហើយ ទ្រង់ប្រាប់ឲ្យជនទាំងនោះស្គាល់ព្រះអង្គ រួចក៏យាងទៅកាន់លំនៅរបស់ខ្លួនវិញ ។ សូម្បីជនទាំងឡាយមានព្រាហ្មណ៍ជាដើម កាលធ្វើបុណ្យមានឲ្យទានជាដើម រស់នៅដរាបអស់អាយុ ក៏បានកើតក្នុងទេវលោក ។

ព្រះសាស្តានាំព្រះជាតកនេះមកហើយ ទ្រង់ដកសរគឺសេចក្តីសោក របស់ឧបាសកនោះបានហើយ ព្រះអង្គប្រកាសសច្ចធម៌ឲ្យក្រៃលែងឡើងទៅ កាលចប់សច្ចធម៌ ឧបាសកបានតាំងនៅក្នុងសោតាបត្តិផល ។

ឧរគបេតវត្ថុ ចប់ ៕

(បរមត្ថទីបនី អដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ បេតវត្ថុ ឧរគវគ្គ ឧរគបេតវត្ថុ បិដកលេខ ៥៦ ទំព័រ ១៨)

ថ្ងៃ សុក្រ ១២ កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ២១ ខែ កញ្ញា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ.